# ការផ្សព្វផ្សាយសារ



*ឯកសារកំណត់ហេតុ*

*សម្រាប់*

*មន្ត្រីផ្នែកទំនាក់ទំនងកម្ពុជាធ្វើការងារទាក់ទងមេរោគអេដស៍ និងជម្ងឺអេដស៍*

ដោយ ហ្សូណា ឡយដី

២០០៥

# មាតិការឿង


តើយើងជាអ្នកណា?

ស្វែងយល់ពីអ្នកដែលយើងត្រូវបំរើ

វិធីច្នៃប្រឌិតដើម្បីផ្សព្វផ្សាយសាររបស់យើង

ផ្សព្វផ្សាយសារ : បញ្ជីត្រួតពិនិត្យ

ជំនាញទំនាក់ទំនងដោយផ្ទាល់មាត់

កសាងទំនាក់ទំនងដោយវិជ្ជមានជាមួយប្រព័ន្ធផ្សព្វផ្សាយ

យុទ្ធនាការរបស់ប្រព័ន្ធផ្សព្វផ្សាយ

ការសរសេរសេចក្តីប្រកាសព័ត៌មាន

ការគ្រប់គ្រងការធ្វើសម្ភាសន៍តាមវិទ្យុ

ចំណុចមានប្រយោជន៍សំរាប់ទូរទស្សន៍




**តើយើងជាអ្នកណា?**

*មុនពេលយើងធ្វើការពិភាក្សាពីជំនាញផ្នែកទំនាក់ទំនងនោះ ចូរយើងពិភាក្សាពីបញ្ហាថាតើ យើងជាអ្នកណា សិនហើយតើយើងចង់ធ្វើអ្វីខ្លះ?*

១-ចូរគិតពីអង្គការស្ថាប័នដែលអ្នកកំពុងធ្វើការ ។ ចូរស្រមៃថាអ្នកកំពុងរៀបរាប់ពីអង្គការស្ថាប័ននេះទៅឱ្យមិត្តម្នាក់ស្តាប់ ។ ចូររៀបរាប់តែមួយប្រយោគប៉ុណ្ណោះពីអ្វីដែលអង្គការស្ថាប័នរបស់ អ្នកកំពុងព្យាយាមដើម្បីសំរេចឱ្យបាន ។

..................................................................................................................................

..................................................................................................................................

១- ប្រសិនបើកិច្ចការរបស់អង្គការស្ថាប័របស់អ្នកបានទទួលជោគជ័យនោះ តើជីវភាពរស់នៅរបស់ប្រជាជននៅក្នុសហគមន៍ នឹងត្រូវបានកែលំអដូចម្តេចដែរ? តើនឹងមានការផ្លាស់ប្តូរជាវិជ្ជមានដូចម្តេចខ្លះ? ឧ. តើ នឹងមានការយោគយល់គ្នា និងការសណ្តោសគ្នាច្រើនជាងមុនទេក្នុងចំណោមប្រជាជនដែលមានជម្ងឺអេដស៍នោះ?

..................................................................................................................................

..................................................................................................................................

២- តើរូបភាព ( ឬ "សម្លេង" ) របស់អង្គការស្ថាប័នរបស់អ្នកមានអ្វីខ្លះ? តើអ្នកចង់ឱ្យប្រជាជនយល់ឃើញដូចម្តេចពីអ្នក? ចូរសរសេរពាក្យរៀបរាប់ពីបុគ្គលិកលក្ខណៈរបស់អង្គការស្ថាប័នរបស់អ្នក ( ឧ. ស្និទ្ធស្នាល យកចិត្តទុកដាក់ ចេះជួយយកអាសារ ) ។

..................................................................................................................................

..................................................................................................................................

៣- តើប្រជាជន ( និងប្រព័ន្ធផ្សព្វផ្សាយ ) យល់ខុសអ្វីខ្លះអំពីអង្គការស្ថាប័នរបស់អ្នក និងការងារដែលអ្នកធ្វើ? តើហេតុអ្វីបានជាអ្នកគិតថាពួកគេយល់ខុស?

..................................................................................................................................

..................................................................................................................................

## **ស្វែងយល់ពីអ្នកដែលយើងត្រូវបម្រើ** (Understanding Who We Serve )

ទៅជួបប្រជាជន

រៀនសូត្រពីពួកគេ

ចាប់ផ្តើមពីអ្វីដែលពួកគេដឹង

កសាងពីអ្វីដែលពួកគេដឹង

ចាប់ផ្តើមឡើងសន្សឹម១

*( គំរោង Hashi - Tanzania )*

ជួនកាលអង្គការស្ថាប័នទាំងឡាយប្រើពាក្យពេចន៍បែបសោះកក្រោះបន្តិចដើម្បីរៀបរាប់ពីមនុស្ស ដែលពួកគេធ្វើការបំរើ ។ ឧ. ដូចជាពាក្យ " អតិថិជន "អ្នកទទួល" ឬ "អ្នកទទួលផលប្រយោជន៍ " ។

ពាក្យពេចន៍បែបនេះមិនមានប្រយោជន៍ណាស់ទេ ។ ហេតុអ្វី? ពីព្រោះវាធ្វើឱ្យយើងភ្លេចថាយើង កំពុងធ្វើទំនាក់ទំនងជាមួយមនុស្ស គឺជាមនុស្សដែលមានគំនិតរបស់ពួកគេផ្ទាល់ និងមានបទ ពិសោធន៍ និងគតិបណ្ឌិតជាច្រើន ។

ការធ្វើទំនាក់ទំនងពិតប្រាកដ គឺការធ្វើទំនាក់ទំនងទៅវិញទៅមក ។ វាមិនមែនត្រឹមតែនិយាយគ្នា ប៉ុណ្ណោះទេ តែគឺការសាប់គ្នាផងដែរ ។ ដូចជាសុភាសិតបូរាណបាននិយាយថា : " *យើងមានត្រចៀក ពីរ និងមាត់មួយ ហេតុនេះយើងគួរតែស្តាប់ឱ្យបានពីរដងច្រើនជាងការដែលយើងនិយាយ! "*

នៅពេលដែលយើងធ្វើទំនាក់ទំនង ការមានសារល្អ ហើយច្បាស់លាស់ គឺនៅមិនទាន់គ្រប់គ្រាន់នៅ ឡើយទេ ។ យើងត្រូវសួរខ្លួនយើងដោយសំនួរទាំងនេះ :

- **តើប្រជាជនត្រៀមខ្លួនបានដូចម្តេចខ្លះដើម្បីទទួលសាររបស់យើងនោះ?**
- **តើពួកគេមានចំណេះដឹងអ្វីជាមុនខ្លះ?**
- **តើមានអ្វីខ្លះដែលអាចរារាំងពួកគេមិនឱ្យបើកចំហរចំពោះសាររបស់យើង?**

សូមចាំថា : យើងចង់ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីឱ្យដល់ប្រជាជនដែលមានសារៈសំខាន់បំផុត។ ហេតុនេះ មុនពេលដែលយើងបង្កើតសាររបស់យើង យើងត្រូវតែយល់ពីអ្វីដែលប្រជាជនមានអារម្មណ៍ ត្រូវការ និងដឹងរួចទៅហើយ។

## **វិធីច្នៃប្រឌិតដើម្បីផ្សព្វផ្សាយសាររបស់យើង** ( Creative Ways To Communicate Our Messages )

តើអង្គការស្ថាប័នរបស់អ្នកធ្វើទំនាក់ទំនងជាមួយមនុស្សដែលអ្នកបំរើតាមវិធីណាខ្លះ? ចូរគិតពិចារណាពីសំនួរខាងក្រោម :

១. តើអ្នកធ្វើទំនាក់ទំនងទល់មុខគ្នាឬ? តាមរយៈការប្រជុំ ឬសិក្ខាសាលា? ព្រឹត្តការណ៍ផ្សេងៗទៀត?

..........................................................................................................................

..........................................................................................................................

២. តើអង្គការស្ថាប័នរបស់អ្នកផលិតឯកសារអ្វីខ្លះ? ប័ណ្ណប្រកាស លិខិតដំណឹង លិខិតខ្លីៗ?

..........................................................................................................................

..........................................................................................................................

៣. តើអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអ្វីខ្លះ? ( វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្ដី? )

..........................................................................................................................

..........................................................................................................................

៤. តើអ្នកធ្លាប់ប្រើប្រាស់វប្បធម៌បូរាណ ឬក៏ប្រព័ន្ធផ្សព្វផ្សាយផ្សេងជាវិធីដើម្បីផ្សព្វផ្សាយសាររបស់អ្នកទេ? ចូរឱ្យជាឧទាហរណ៍ :

..........................................................................................................................

..........................................................................................................................

ចូរយើងគិតពិចារណាឱ្យបានច្រើនបន្តិចអំពីសំណួរទី ៣ ។ តើយើងអាចមានគំនិតច្នៃប្រឌិតជាងនេះតាមរបៀបណានៅក្នុងរបៀបដែលយើងប្រើវប្បធម៌បូរាណ ឬក៏ប្រព័ន្ធផ្សព្វផ្សាយផ្សេងដើម្បីផ្សព្វផ្សាយសាររបស់យើងនោះ? នេះគឺជាឧទាហរណ៍មួយចំនួនដែលបានមកពីប្រទេសផ្សេងទៀត ៖

- <u>ការរាំដើម្បីសន្តិភាព ( **Sulawesi, Indonesia** )</u>

ពួកមេដឹកនាំសហគមន៍នៅលើកោះ **Salawesi** មានការព្រួយបារម្ភពីអំពើហឹង្សាដែលចេះតែកើនឡើងរវាងប្រជាជនដែលចេញពីសាសនាផ្សេងៗ ។ ពួកគេបានសំរេចចិត្តរៀបចំពិធីរាំវែកជាប្រពៃណីយ៍មួយដែលហៅថា " **modero** " ។ នៅក្នុងពេលពិធីរាំវែកនោះ ប្រជាជនមកពីសហគមន៍សាសនាទាំងអស់បាននាំគ្នារាំពេញមួយយប់នៅក្នុងរង្វង់មូលមួយដ៏ធំនៅពេលដែលពួកតន្ត្រីករក្នុងមូលដ្ឋានបាននាំគ្នាស្រែកច្រៀង ។ បទចម្រៀងបានរៀបរាប់ពីទំនាស់នៅពេលថ្មីៗ តែពួកគេបាននិយាយពីសេចក្តីត្រូវការសន្តិភាព និងការចុះសម្រុងគ្នា ។ នៅពេលដែលប្រជាជនកំពុងនាំគ្នារាំវែក ពួកគេគ្មានឱកាសដើម្បីវាយតប់គ្នា ឬឈ្លោះប្រកែកគ្នាឡើយ ។ **Modero** បានជួយស្តារឡើងវិញនូវមិត្តភាព និងការជឿទុកចិត្តគ្នានៅក្នុងសហគមន៍នោះ ។

- <u>សារុងដែលមានសារសុខភាព ( តង់ហ្សានី អាហ្វ្រិកខាងកើត )</u>

នៅប្រទេសតង់ហ្សានី ស្រីៗស្លៀកសារុងធ្វើពីកប្បាសដ៏ស្រស់ដែលមានសុភាសិតពីបូរាណ និងពាក្យចាស់បូរាណដែលប្រកបដោយគតិបណ្ឌិតបោះពុម្ពនៅលើសារុងនោះផង ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនមានគំនិតឆ្លាតវៃបានប្រើប្រាស់សារុងទាំងនេះជាវិធីដើម្បីផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាទាំងឡាយដូចជាការបំបៅដោះកូន និងអាហារូបត្ថម្ភកុមារ ។ មិនយូរប៉ុន្មាន ការស្លៀកសារុងដ៏ពិសេសទាំងនេះបានក្លាយទៅជារឿងទាន់សម័យបំផុត!

- <u>ការដើរក្បួនរបស់បុរសប្រឆាំងនឹងការចាប់រំលោភ ( **Alexandra** អាហ្វ្រិកខាងត្បូង )</u>

កាលពីពីរបីឆ្នាំមុន អង្គការក្រៅរដ្ឋាភិបាលអាហ្វ្រិកខាងត្បូងដ៏តូចមួយដែលដោះស្រាយរឿងចាប់រំលោភ និងអំពើហឹង្សាក្នុងគ្រួសារនោះបានរៀបចំក្បួនបាតុកម្មមួយដែលមានលក្ខណៈខុសប្លែកពីគេ ។ នៅព្រឹក

ថ្ងៃសៅរ៍មួយ មានយុវជនជាច្រើនរយនាក់បានដើរជាក្បួនកាត់តាមដងវិថីនានា នៃទីក្រុង **Alexandra** (ជាសហគមន៍មួយដែលមានបញ្ហាការចាប់រំលោភយ៉ាងធ្ងន់ធ្ងរ )។ ក្រុមយុវជនបាននាំគ្នាកាន់បដារ ដែលមានពាក្យស្លោកដាក់ថា " បុរសពិតមិនចាប់រំលោភគេទេ " ហើយនាំគ្នាស្រែកច្រៀងនូវចម្រៀង ដែលជំរុញឱ្យពួកប្រុសៗបញ្ឈប់សកម្មភាពអកុសលកិរិយារបស់ខ្លួន។ នៅពេលដែលពួកគេបានដើរទៅដល់ ទីលានបាល់ទាត់ក្នុងមូលដ្ឋាន ពួកស្រីៗនៅទីក្រុង **Alexandra** បានកំពុងរង់ចាំនៅទីនោះដើម្បីស្វាគមន៍ ពួកគេ។ ពួកស្រីៗទាំងនោះបានរៀបចំពិធីបែបប្រពៃណីយ៍មួយដើម្បីលាងសំអាត និងអភ័យទោសឱ្យ ដែលជាពិធីមួយដែលជាធម្មតាត្រូវគេរៀបចំធ្វើឡើងសំរាប់ពួកអ្នកចម្បាំងអាហ្វ្រិកដែលវិលត្រឡប់មក ពីធ្វើសង្គ្រាមវិញ។ នេះគឺជានិមិត្តរូបមួយដើម្បីនាំយកមកនូវការជាសះស្បើយ និងការអភ័យទោសមក ឱ្យសហគមន៍មួយដែលពោរពេញដោយការឈឺចាប់។ បន្ទាប់ពីពិធីនោះមក មានបុរសជាច្រើនបានត្រ ឡប់មកអង្គការក្រៅរដ្ឋាភិបាលវិញ ហើយបាននិយាយរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេក្នុង ភាពជាអ្នកចាប់គេរំលោភ និងដើម្បីរកវិធីកែប្រែជីវិតរបស់ពួកគេឱ្យកាន់តែប្រសើរឡើង។

មានឧទាហរណ៍ផ្សេងទៀតជាច្រើនស្តីពីវិធីច្នៃប្រឌិតដើម្បីផ្សព្វផ្សាយសារទាំងឡាយ។ តើអ្នកមាន យោបល់ដូចម្តេចដែរពីសារទាំងនេះ?

- សហការជាមួយក្រុមល្ខោនក្នុងសហគមន៍មូលដ្ឋានដើម្បីបង្កើតរឿងល្ខោនមួយនិយាយអំពី បញ្ហាដែលអ្នកចង់ផ្សព្វផ្សាយ។ សម្តែងរឿងល្ខោននោះនៅតាមសាលារៀន ឬតាមទីផ្សារ ឬកន្លែងណាមួយដែលអ្នកតែងតែប្រទះទស្សនិកជនដែលជាគោលដៅរបស់អ្នកជាធម្មតា នោះ។ នៅចុងបញ្ចប់ នៃការសម្តែង ត្រូវរៀបចំឱ្យមានការប្រជុំសំរាប់សួរ និងឆ្លើយមួយជា មួយប្រជាជនដែលបានទស្សនារឿងល្ខោននោះ។
- សហការជាមួយវិចិត្រករក្នុងមូលដ្ឋានដើម្បីគូររូបមួយផ្ទាំងធំសំរាប់ដាក់ខាងក្រៅ (ផ្ទាំងគំនូរ គូរលើជញ្ជាំង)ព្យួរលើជញ្ជាំងនៅក្នុងទីសាធារណៈ (ដូចជាមន្ទីរពេទ្យ ឬគ្លីនិក)។ រូបភាព នេះអាចមានសសេរសារទាំងឡាយដែលអ្នកចង់ឱ្យប្រជាជនគិតគូរពិចារណាអំពីវា។
- សហការជាមួយកីឡាករដ៏ល្បីឈ្មោះក្នុងស្រុកម្នាក់ គឺជាអ្នកដែលមានប្រជាប្រិយភាពបំផុត ជាមួយទស្សនិកជនដែលជាទីសដៅរបស់អ្នក។ អញ្ជើញបុគ្គលនេះឱ្យធ្វើជា "សម្លេង" របស់

អង្គការស្ថាប័នរបស់អ្នក។ ឧ. ប្រសិនបើអ្នកព្យាយាមបញ្ចុះបញ្ចូលយុវវ័យកុំឱ្យជក់គ្រឿងញៀននោះ ពួកគេ នឹងទទួលយកសារនោះបានយ៉ាងងាយពីនរណាម្នាក់ដែលពួកគេស្ងើចសរសើរ ( ដូចជាតារាបាល់ទាត់ ) ជាងពីនរណាម្នាក់ដែលមកពីអង្គការក្រៅរដ្ឋាភិបាល!

- តើប្រជាជនចូលចិត្តបង្ហោះខ្លែងដែរទេនៅក្នុងសហគមន៍របស់អ្នក? រៀបចំពិធីបុណ្យមួយដែលមានបង្ហោះខ្លែងដែលមានដាក់សារ និងដំណឹងដែលអ្នកចង់ផ្សព្វផ្សាយ។ នៅចុងបញ្ចប់នៃថ្ងៃនោះ គេគ្រប់គ្នាអាចព្រលែងខ្លែងនោះដើម្បីឱ្យដំណឹងនោះអាចធ្វើដំណើរបានឆ្ងាយ។

## ផ្សព្វផ្សាយសារនោះ៖ បញ្ជីត្រួតពិនិត្យ (Getting the message across: checklist )

*នេះគឺជាបញ្ជីត្រួតពិនិត្យមួយដែលជួយឱ្យអ្នករៀបចំផែនការមានប្រសិទ្ធភាពដើម្បីផ្សព្វផ្សាយសាររបស់អ្នក។ ប្រើប្រាស់បញ្ជីត្រួតពិនិត្យនៅពេលដែលអ្នកពិភាក្សាពីយុទ្ធសាស្ត្រទំនាក់ទំនងរបស់អង្គការស្ថាប័នរបស់អ្នក។*

### អ្វី

តើអ្វីទៅដែលជាសារគន្លឹះដែលយើងចង់ផ្សព្វផ្សាយ?

តើអ្វីទៅដែលនឹងអូសទាញប្រជាជនឱ្យទទួលយកសារនោះ?

តើយើងចង់ឱ្យប្រជាជនធ្វើអ្វីខ្លះបន្ទាប់ពីពួកគេបានស្ដាប់សាររបស់យើងហើយនោះ? ( ឧ. ឈប់ប្រើម្ជុលរួមគ្នា ហើយប្រើប្រាស់ស្រោមអនាម័យ ) ។

### ហេតុអ្វី

តើហេតុអ្វីបានជាយើងចង់ឱ្យប្រជាជនទទួលយកសាររបស់យើង?

តើហេតុអ្វីបានជាប្រជាជនមិនចង់ទទួលយកសាររបស់យើង?

### នរណា

តើនរណាជាទស្សនិកជនដែលជាទីសដៅរបស់យើង?

តើពួកគេប្រហែលជាស្តាប់នរណាជាង? (នរណាម្នាក់មកពីអង្គការស្ថាប័នរបស់យើងឬ? នរណាម្នាក់មកពីសហគមន៍របស់យើងផ្ទាល់ឬ? តន្ត្រីករ ឬក៏កីឡាករដែលល្បីឈ្មោះ?)

## តាមវិធីណា

តើយើងនឹងបញ្ជូនសារនោះតាមវិធីណា? តាមអត្ថបទមួយនៅក្នុងកាសែតឬ? តាមសិក្ខាសាលា ឬការប្រជុំនៅក្នុងសហគមន៍? តាមប័ណ្ណប្រកាស? តាមរយៈលិខិតតូចៗ? តាមរយៈរឿងល្ខោន ឬចំរៀងមួយបទដ៏ពិសេស? តាមរយៈការប្រើវប្បធម៌បូរាណ?

## កន្លែងណា

តើយើងគួរទៅកន្លែងណាដើម្បីផ្សព្វផ្សាយសារនោះ? ទៅស្ថានីយវិទ្យុ? កាសែត? វិទ្យាល័យ? ក្លឹបរាត្រី?

## នៅពេលណា

តើយើងនឹងបញ្ជូនសារនោះនៅពេលណា? តើប្រជាជនប្រុងប្រៀបខ្លួនដើម្បីស្តាប់សារនោះនៅពេលណា? ប្រសិនបើយើងកំពុងសម្តែងល្ខោនឱ្យស្រីៗនៅក្នុងផ្សារមើល តើយកល្អគួរតែសម្តែងវានៅពេលព្រឹក ឬក៏នៅពេលរសៀលពេលដែលពួកគេរតូវរៀបចំឥវ៉ាន់ត្រឡប់ទៅផ្ទះវិញ? ប្រសិនបើយើងត្រូវធ្វើការសម្តែងតាមវិទ្យុសំរាប់ពួកក្មេងជំទង់ តើពួកគេចង់ស្តាប់នៅពេលណា?

## ជំនាញទំនាក់ទំនងដោយផ្ទាល់មាត់ ( Verbal Communication Skills )

អ្នកធ្វើទំនាក់ទំនងពូកែបំផុតនៅក្នុងពិភពលោក គឺមានចំណុចរួមមួយ : គឺសមត្ថភាពក្នុងការធ្វើឱ្យទស្សនិកជនរបស់ខ្លួនកំណត់បាននូវសាររបស់ខ្លួន ហើយចងចាំវាបាន។

តើយើងធ្វើដូច្នេះតាមវិធីណា?

១. ត្រូវនិយាយប្រាប់ឱ្យបានច្បាស់លាស់។ កុំផ្តល់ស្ថិតិដែលស្មុគស្មាញ។

២. ចូរស្រមៃថាអង្គការក្រៅរដ្ឋាភិបាលមួយកំពុងធ្វើយុទ្ធនាការប្រឆាំងនឹងជម្ងឺអាសន្នរោគ។ អ្នកចង់ឱ្យប្រជាជនយល់ថាជម្ងឺអាសន្នរោគ គឺជាជម្ងឺមួយដែលមានគ្រោះថ្នាក់ពិតប្រាកដ និងយល់ថា

ជម្ងឺនេះអាចឆ្លងដល់ពួកគេដោយផ្ទាល់ប្រសិនបើពួកគេមិនបានប្រុងប្រយ័ត្នជាមុនឱ្យបានត្រឹមត្រូវទេ។

ចូរកុំនិយាយថា : ប្រជាពលរដ្ឋចំនួន ២០% ប្រហែលជាត្រូវប្រឈមនឹងគ្រោះថ្នាក់ នៃជម្ងឺអាសន្នរោគនៅក្នុងរដូវវស្សានេះ។

ជំនួសពីនេះត្រូវនិយាយថា : សូមអ្នកគិតដល់មនុស្ស ៤ នាក់ដែលអ្នកស្គាល់។ ក្នុងនោះ អាចមានម្នាក់មានជម្ងឺអាសន្នរោគនៅរដូវវស្សានេះ។ វាអាចជារូបអ្នកឯងផង!

នៅពេលនេះ អ្នកធ្វើឱ្យមិត្តអ្នកស្តាប់របស់អ្នកយកចិត្តទុកស្តាប់ទាំងស្រុង។ គាត់ត្រៀមខ្លួនជាស្រេចនឹងទទួលសារសុខភាពរបស់អ្នក។

២-ចូរនិយាយឡើងវិញនូវ*ពាក្យសំខាន់ៗ*និង*គំនិតសំខាន់ៗ*

ប្រសិនបើអ្នកចង់ឱ្យទស្សនិកជនរបស់អ្នកចងចាំព័ត៌មានសំខាន់ៗ ត្រូវនិយាយវាឡើងវិញ - ជាញឹកញាប់ត្រូវប្រើភាសាសមញ្ញ ហើយច្បាស់លាស់ដើម្បីបង្ហាញពីគំនិតសំខាន់ៗ។

៣-សួរ*សំណួរ*

នៅពេលដែលអ្នកសួរសំណួរមួយ ទស្សនិកជនរបស់អ្នក នឹងតភ្ជាប់ជាមួយអ្នកភ្លាម។ ពួកគេចាប់ផ្តើមនិយាយប្រាប់ពីអ្វីដែលអ្នកកំពុងនិយាយចំពោះបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ សំនួរជួយបើកចិត្តគំនិត និងជួយលើកទឹកចិត្តឱ្យមានការសហការច្រើនថែមទៀតរវាងអ្នក និងមនុស្សដែលអ្នកកំពុងនិយាយរក។ ឧ. " នៅពេលដែលអ្នកគិតដល់នរណាម្នាក់ដែលកំពុងរស់នៅដោយមានផ្ទុកហ៊ីវ/អេដស៍ តើអ្នកមើលឃើញរូបភាពអ្វីនៅក្នុងចិត្តរបស់អ្នក?"

៤-*បំផុសគ*ដោយមិន " ប្រដៅ " ឬធ្វើជា "ឆ្លាត "ទេ

អ្នកពូកែធ្វើទំនាក់ទំនងមិនដែលដាក់ខ្លួនឱ្យខ្ពស់ជាងទស្សនិកជនទេ។ ផ្ទុយទៅវិញ គេនិយាយទៅកាន់ទស្សនិកជនក្នុងកំរិតស្មើភាពគ្នា។ ដូចបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលឥណ្ឌូណេស៊ីម្នាក់ពន្យល់ថា :

" នៅពេលដែលអ្នកនិយាយទៅរកគេ ត្រូវផ្លាស់ប្តូរគំនិតជាមួយគេ កុំនិយាយប្រាប់ពួកគេថាតើត្រូវធ្វើដូចម្តេច! ត្រូវចូលទៅរកគេដោយការគោរពដូចជាមនុស្សដែលយល់ពីបញ្ហារបស់ពួកគេអីចឹង។ សើចលេងជាមួយពួកគេ ច្រៀងជាមួយគ្នា ហូបជាមួយគ្នា។ ធ្វើតាមវិធីនោះ វានឹងធ្វើឱ្យអ្នកដូចជាបងប្អូននឹងគ្នាអីចឹង។"

នេះគឺជាសំនួរមួយចំនួនដែលគេតែងសួរក្នុងពេលធ្វើទំនាក់ទំនងដោយផ្ទាល់មាត់ :

**<u>តើខ្ញុំធ្វើដូចម្តេចដើម្បីឱ្យមានអារម្មណ៍ទុកចិត្តជាងមុន?</u>**

ព្យាយាមនិយាយឡើងវិញនូវ " ក្បួនបន្ធូរអារម្មណ៍ " ដ៏ងាយស្រួលនេះ[១] មកកាន់ខ្លួនឯង។ ឱ្យរាងកាយរបស់អ្នកឆ្លើយតបនឹងពាក្យទាំងឡាយដូចជា :

- ខ្នងខ្ញុំវែង ហើយធំ
- កខ្ញុំសេរី
- ស្មាខ្ញុំសេរី
- ខ្ញុំមានអារម្មណ៍ថាក្បាលរបស់ខ្ញុំកំពុងលូតចេញពីខ្នងរបស់ខ្ញុំ
- ខ្ញុំអាចមានអារម្មណ៍ថាកៅអី ( ឬដី ) កំពុងទប់ខ្ញុំ

**<u>តើខ្ញុំអាចនៅស្ងប់ចិត្តដូចម្តេចទៅនៅពេលដែលនរណាម្នាក់គឃ្លើន ឬមានមនោសញ្ចេតនានោះ?</u>**

ដកដង្ហើមឱ្យវែង ហើយព្យាយាមធ្វើចិត្តឱ្យស្ងប់។ កុំយកភាពគឃ្លើនតទល់ជាមួយភាពគឃ្លើន : វានាំឱ្យអ្នកមានលក្ខណៈអវិជ្ជមាន ហើយស្ថិតក្នុងការការពារខ្លួន។ ត្រូវទទួលយកមនោសញ្ចេតនារបស់បុគ្គលផ្សេងទៀត ហើយបន្ទាប់មកបង្ហាញពួកគេថាអ្នកចង់ស្វែងយល់ពីបញ្ហាដែលចេញពីទស្សនៈរបស់ពួកគេ។ ជាញឹកញាប់ ស្តាប់ទៅពួកគេហាក់ដូចជាខឹងនៅពេលដែលពួកគេទទួលរងការឈឺចាប់ពីដំបៅ ឬការឈឺចាប់ផ្លូវចិត្ត។ ត្រូវយល់ពីស្ថានការណ៍របស់ពួកគេ ហើយមិនត្រូវវិនិច្ឆ័យពីពួកគេទេ :

---

[១] យកលំនាំតាម " សម្លេងរបស់អ្នក និងវិធីដើម្បីប្រើប្រាស់សម្លេងនោះ " ដោយ Cicely Berry (Virgin Books, 1994 )

ឧ. " ខ្ញុំអាចស្តាប់ឮថាអ្នកមានអារម្មណ៍ខ្លាំងក្លាណាស់ពីបញ្ហានេះ។ តើអ្នកអាចជួយឱ្យខ្ញុំយល់ផងបានទេថាហេតុអ្វីបានជាអ្នកមានអារម្មណ៍បែបនេះ? "

*(សូមមើលទៅផ្នែកក្រោយទៀតពីវិធីដើម្បីចាត់ការជាមួយអ្នកកាសែតដែលមានឬកពារគឃ្លើន "*

**<u>តើខ្ញុំអាចប្រើភាសាកាយវិការដូចម្តេចដើម្បីឱ្យមានលក្ខណៈកាន់តែវិជ្ជមាននោះ?</u>**

ភាសាកាយវិការប្រែប្រួលយោងទៅតាមវប្បធម៌ និងសាវតាសង្គម។ ប៉ុន្តែ នេះគឺជាឧទាហរណ៍ខ្លះស្តីពីភាសាកាយវិការដែលមានលក្ខណៈអវិជ្ជមាន។ ត្រូវឱ្យច្បាស់ថាឧទាហរណ៍ទាំងនេះមិនពាក់ព័ន្ធនឹងអ្នកទេ!

- **ភាសាកាយវិការបិទជិត** ដែលមិនអញ្ជើញអ្នកដទៃឱ្យធ្វើទំនាក់ទំនងជាមួយ ហើយដែលបិទទ្វារឃាំងអ្នកផ្សេងទៀតឱ្យនៅខាងក្រៅ ( ដូចជាអោបដៃ/ គ្មានទំនាក់ទំនងខ្សែភ្នែក )។
- **ភាសាកាយវិការបែបគំរាមកំហែង** ដែលមនុស្សម្នាក់រំលោភលើទីកន្លែងរបស់មនុស្សម្នាក់ទៀតដោយការខិតចូលមកកៀកពេក ឬដោយការប្រើប្រាស់កាយវិការឈ្លានពាន។
- **ភាសាកាយវិការបែបរសាប់រសល់** ដែលបង្ហាញពីការភ័យខ្លាច ខ្វះជំនឿទុកចិត្ត និងគ្មានឆន្ទះដើម្បីចូលរួមក្នុងការប្រស្រ័យទាក់ទងគ្នា (អោនក្បាលចុះ រួញខ្លួនចេញ ប្រហែលជាញញើតញញើមមិនហ៊ានមើលមុខអ្នកដទៃ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះអាចប្រែប្រួលដោយយោងតាមបរិបទវប្បធម៌ )។

ហេតុនេះ តើយើងគួរតែបង្កើតភាសាកាយវិការប្រភេទណា?

- **ភាសាកាយវិការដោយបើកចំហរ** ដែលបង្ហាញពីភាពស្និទ្ធស្នាល និងឆន្ទះដើម្បីធ្វើទំនាក់ទំនង និងដើម្បីស្តាប់ (ញញឹម មានឥរិយាបទបើកចំហរ ហើយមានតុល្យភាព មានការគោរពចំពោះកន្លែងអ្នកដទៃ )។

## តើខ្ញុំធ្វើទំនាក់ទំនងជាមួយទស្សនិកជនដ៏ច្រើនតាមវិធីណា?

វាជាការងាយស្រួលទេ : ចូរផ្តោតលើសាររបស់អ្នក ហើយជានិច្ចកាលស្រមៃថាអ្នកកំពុងនិយាយទៅកាន់មនុស្សតែម្នាក់គត់។ ប្រសិនបើអ្នកស្រមៃឃើញមនុស្សតែម្នាក់នោះ វាជាការងាយស្រួលច្រើនជាងដើម្បីនិយាយក្នុងរបៀបមួយដែលមានអំនាច។

ប៉ុន្តែ ត្រូវច្បាស់លាស់ថាភាសាកាយវិការរបស់អ្នកមានរាប់បញ្ចូលគេគ្រប់គ្នាដែលជាទស្សនិកជននោះ។ ត្រូវក្រោកឈរ ឬអង្គុយដើម្បីឱ្យខ្លួនអ្នកអាចមើលឃើញគេគ្រប់គ្នាបានយ៉ាងងាយ។ ត្រូវប្រើភ្នែកសម្លឹងមើលឱ្យបានគ្រប់គ្នា។

## តើខ្ញុំអាចកែលំអជំនាញផ្នែកទំនាក់ទំនងតាមទូរស័ព្ទរបស់ខ្ញុំតាមវិធីណា?

នៅពេលដែលអ្នកលើកទូរស័ព្ទភ្លាម អ្នកគឺជា "សម្លេង" របស់អង្គការស្ថាប័នរបស់អ្នកហើយដោយមិនគិតថាតើអ្នកកំពុងនិយាយជាមួយអ្នកណាទេ។

ហេតុនេះប្រសិនបើអ្នកបញ្ចេញសម្លេងខឹង ធុញទ្រាន់ ឬនឿយណាយ នោះហើយគឺជាពេលដែលអ្នកទូរស័ព្ទហៅមកនោះយល់ឃើញពីអង្គការស្ថាប័នរបស់អ្នក។ ផ្ទុយទៅវិញប្រសិនបើអ្នកបញ្ចេញសម្លេងបែបយកចិត្តទុកដាក់ និងក្នុងលក្ខណៈវិជ្ជមាននោះ នោះគឺជាពេលដែលអ្នកផ្តល់មុខមាត់ដល់អង្គការស្ថាប័នអ្នកហើយ។

តើអ្វីទៅជាមុខមាត់របស់អង្គការក្រៅរដ្ឋាភិបាលរបស់អ្នកនៅពេលដែលមានមនុស្សទូរស័ព្ទមកការិយាល័យរបស់អ្នកនោះ?

នេះគឺជាចំនុចមានប្រយោជន៍ខ្លះដើម្បីជួយឱ្យអ្នកអភិវឌ្ឍការទូរស័ព្ទឱ្យកាន់តែមានលក្ខណៈបែបវិជ្ជាជីវៈនោះ :

- នៅពេលដែលអ្នកចាប់ផ្តើមទូរស័ព្ទហៅ ឬឆ្លើយទូរស័ព្ទភ្លាម អ្នកត្រូវត្រៀមខ្លួនផ្តល់ការយកចិត្តទុកដាក់ចំពោះមនុស្សម្ខាងទៀតឱ្យបាន ១០០%។ ត្រូវឈប់និយាយរកអ្នកផ្សេងទៀតនៅក្នុងការិយាល័យ។ ហើយឈប់វាយកំព្យូទ័រភ្លាម! ចូរចាំថានៅពេលដែលយើងធ្វើទំនាក់ទំនងតាម

ទូរស័ព្ទយើងមិនអាចមើលគ្នាឃើញទេ។ ចំនុចនេះមានន័យថាយើងអាចងាយភ័ន្តច្រឡំ ឬមួម៉ៅ ប្រសិនបើយើងមិនប្រុងប្រយ័ត្ន។

- ត្រូវត្រៀមក្រដាស់ និងប៊ិចរួចជាស្រេចដូច្នេះអ្នកអាចធ្វើការកត់ត្រាពីការសន្ទនាបាន។
- ត្រូវព្យាយាមគួរសម ស្និទ្ធស្នាល ច្បាស់លាស់ និងមានលក្ខណៈវិជ្ជមានគ្រប់ពេលវេលាទោះបីជាបុគ្គលម្ខាងទៀតច្របូលច្របល់ ឬគ្មានការគួរសមក៏ដោយ។
- ត្រូវឆ្លើយទូរស័ព្ទឱ្យបានច្បាស់លាស់ ធ្វើគារវកិច្ច រួចហើយប្រាប់ឈ្មោះអង្គការស្ថាប័នរបស់អ្នក។ ប្រាប់ថាខ្លួនអ្នកជានរណា ហើយក៏ត្រូវសួរឈ្មោះអ្នកដែលទូរស័ព្ទមកនោះដែរ។
- សូមញញឹមនៅពេលដែលអ្នកឆ្លើយទូរស័ព្ទ : ការញញឹមគឺស្មើនឹងការធ្វើទំនាក់ទំនងតាមក្រសែភ្នែក។ ការញញឹមក៏ជួយលើកសម្លេងរបស់អ្នកដែរ ហើយធ្វើឱ្យអ្នកហាក់ដូចជាកាន់តែក្លៀវក្លា និងមានលក្ខណៈវិជ្ជាជីវៈឡើង។
- ព្យាយាមកុំបញ្ចេញសម្លេងអវិជ្ជមាន។ ប្រសិនបើអ្នកមិនអាចជួយអ្នកដែលទូរស័ព្ទមកនោះភ្លាមទេត្រូវផ្តល់ផ្លូវជ្រើសរើសផ្សេង។ ឧទាហរណ៍ : ប្រសិនបើអ្នកមិនដឹងចម្លើយចំពោះសំណួរមួយ សូមកុំនិយាយថា "ខ្ញុំមិនដឹងទេ "។ គប្បីគួរនិយាយថា " តើខ្ញុំអាចជំរាបព័តិមាននោះជូនលោកនៅពេលក្រោយបានទេ?"
- ជានិច្ចកាលត្រូវនិយាយប្រាប់អ្នកហៅនោះពីអ្វីដែលអ្នកប្រុងធ្វើ ជាពិសេសនៅពេលដែលអ្នកត្រូវហុចទូរស័ព្ទនោះទៅឱ្យបុគ្គលិកម្នាក់ទៀត។ មិនត្រូវគ្រាន់តែនិយាយថា " ចាំមួយភ្លែត" ទេ គប្បីត្រូវនិយាយថា :" ខ្ញុំគិតថាលោកនាយករបស់ខ្ញុំប្រហែលជាអាចជួយលោកពីបញ្ហានោះបាន ។ តើលោករង់ចាំភ្លែតបានទេ? ខ្ញុំនឹងព្យាយាមតភ្ជាប់ជូនលោក។
- ប្រសិនបើអ្នកកំពុងឆ្លើយតបទូរស័ព្ទ ត្រូវអរគុណអ្នកដែលទូរស័ព្ទហៅ ហើយទុកឱ្យគេដាក់ទូរស័ព្ទមុន។

- ប្រសិនបើអ្នកកំពុងនិយាយជាមួយអ្នកដែលមានកំហឹង ឬអ្នកដែលមានមនោសញ្ចេតនា ត្រូវតាំងចិត្តឱ្យស្ងប់! ចូរចាំថាត្រូវបង្កើតរូបភាពវិជ្ជមាន និងដែលយកចិត្តទុកដាក់ ហើយបង្ហាញថាអ្នកយល់ពីមូលហេតុដែលអ្នកទូរស័ព្ទហៅនោះរកាំចិត្ត។
- ត្រូវនិយាយឡើងវិញនូវព័ត៌មានដែលសំខាន់ដើម្បីជៀសវាងការភ័ន្តច្រឡំ និងដើម្បីឱ្យច្បាស់ថាអ្នកទាំងពីរពិតជាយល់សាច់រឿងដូចគ្នា។ ឧទាហរណ៍ : " ហេតុនេះ ខ្ញុំគួរទៅសាលារៀននៅម៉ោង ២ នៅថ្ងៃពុធ មែនទេ?"



## កសាងទំនាក់ទំនងវិជ្ជមានជាមួយប្រព័ន្ធផ្សព្វផ្សាយ ( Building Positive Relationships With The Media )

មានអង្គការស្ថាប័នជាច្រើនមិនចូលចិត្តប្រព័ន្ធផ្សព្វផ្សាយទេ។ ពួកគេចោទប្រកាន់អ្នកកាសែតពីបទបំផ្លើសការពិត ។
ម្យ៉ាងវិញទៀត អ្នកកាសែតជួនកាលមានអារម្មណ៏ហាក់ដូចជាត្រូវគេញាក់។ ហេតុអ្វីទៅ? ពីព្រោះជាក់ស្តែងអង្គការស្ថាប័ននានាសង្ឃឹមថាអ្នកកាសែតនឹងផ្តល់ការផ្សព្វផសាយដោយសេរីចំពោះបញ្ហាទាំងឡាយដែលជានិច្ចកាលមិនមានតម្លៃជាព័តិមាន។ ក្នុងពេលជាមួយគ្នានោះដែរ អ្នកកាសែតត្រូវគេបន្ទោសដោយសារតែមានឥរិយាបទអវិជ្ជមាននៅពេលណាក៏ដោយដែលពួកគេសួរពីប្រភេទសំនួរដែលអ្នកអាន អ្នកស្តាប់ ឬអ្នកមើលចង់ឱ្យពួកគេសួរនោះ!

ជួនកាល វាមិនមែនជាស្ថានភាពមួយដែលមានជោគជ័យនោះទេ។
ប៉ុន្តែអ្វីក៏ដោយដែលជាការរសាយចិត្តទៅវិញទៅមករបស់យើងនោះ គឺថាយើងត្រូវការប្រព័ន្ធផ្សព្វផ្សាយ ហើយប្រព័ន្ធផ្សព្វផ្សាយត្រូវការយើង។ ទោះជាយ៉ាងណាក្តី យើងត្រូវតែរកវិធីដើម្បីធ្វើការជាមួយគ្នាឱ្យកាន់តែមានលក្ខណៈស្ថាបនាឡើង និងដើម្បីកសាងទំនាក់ទំនងមួយដែលមានលក្ខណៈវិជ្ជមាន និងមានវិជ្ជាជីវៈដោយផ្អែកលើការគោរពជាមូលដ្ឋាន។

ដំបូង យើងត្រូវស្វែងយល់**ថាតើអ្នកកាសែតត្រូវការអ្វី។**
ចម្លើយគឺសមញ្ញណាស់ គឺថាតពួកគេត្រូវការព័តិមាន។ ហេតុនេះ តើយើងអាចរៀនសូត្រដើម្បីកំណត់ព័តិមាននៅក្នុងសាច់រឿងរបស់យើងតាមរបៀបណា?

ប្រសិនបើយើងចាប់ផ្តើមគិតដូចជាអ្នកកាសែតនោះ វាមិនពិបាកពេកទេ។

អ្នកកាសែតដែលពូកែដឹងពីរឿងនោះ។ នៅពេលដែលពួកគេសរសេរសាច់រឿងមួយ ពួកគេគួរតែឆ្លើយទៅនឹងសំនួរពីរ :

១-តើមានរឿងអ្វីកំពុងកើតឡើង?
២-ហេតុនេះតើវាយ៉ាងម៉េច?

សំនួរទីពីរ គឺជាសំនួរដែលសំខាន់ជាងគេពីព្រោះវាផ្តល់ឱ្យនូវមុមព័តិមាន។

ឥឡូវនេះយើងយល់ពីអ្វីឌែលអ្នកកាសែតចង់បានហើយ។ ប៉ុន្តែតើយើងចាប់ផ្តើមកសាងទំនាក់ទំនងមួយឱ្យកាន់តែប្រសើរជាមួយប្រព័ន្ធផ្សព្វផ្សាយតាមវិធីណា? នេះជាចំណុចមានប្រយោជន៏ខ្លះ :

- បង្កើតក្រុមស្នូលអ្នកកាសែតមួយក្រុមដែលអ្នកអាចធ្វើការជាមួយបានដែលមកពីវិទ្យុ ទូរទស្សន៏ និងកាសែត។ ត្រូវឱ្យដឹងថាតើពេលណាជាពេលដែលល្អបំផុតដើម្បីទូរស័ព្ទទៅរកពួកគេ (អ្នកកាសែតមានពេលស្ងប់ស្ងាត់នៅចន្លោះពេលកំណត់ទាំងឡាយ)។ អ្នកក៏អាចនាំពួកគេចេញទៅផឹកកាហ្វេម្តងម្កាល ប្រាប់ពួកគេពីអ្វីដែលអ្នកកំពុងធ្វើ និងអ្វីដែលអ្នកមានផែនការធ្វើទៅថ្ងៃអនាគត។
- ប្រសិនបើអ្នកទទួលបានសេចក្តីរាយការណ៏ជាវិជ្ជមាន ត្រូវទូរស័ព្ទទៅឱ្យអ្នកកាសែតដែលទទួលខុសត្រូវ ហើយនិយាយអរគុណ។
- ប្រសិនបើអ្នកទទួលបានរបាយការណ៏អវិជ្ជមាន ត្រូវសំរេចចិត្តថាតើត្រូវដោះស្រាយដូចម្តេចល្អនោះ។ តើវាមានតម្លៃទេដែលបង្កឱ្យមានជម្លោះ ហើយប្តឹងផ្តល់លោកនិពន្ធនាយកនោះ? ឬក៏អ្នកអាចរកឃើញវិធីបែបការទូតដើម្បីប្តឹងផ្តល់ដោយមិនចងសត្រូវជារៀងរហូតនោះ?
- កុំគ្រាន់តែស្វែងរកការរាយការណ៏ពីប្រព័ន្ធផ្សព្វផ្សាយសំរាប់ព្រឹត្តការណ៏ ឬយុទ្ធនាការតែប៉ុណ្ណោះត្រូវគិតគូឱ្យបានទូលំទូលាយ។ តើកាសែតក្នុងស្រុករបស់អ្នកទទួលយកមតិយោបល់ដែរទេ? ចូរ

សរសេរអត្ថបទមួយអំពីយុទ្ធនាការនៅពេលបច្ចុប្បន្នរបស់អ្នក។ ឬប្រើប្រាស់ " លិខិតទៅកាន់ទំព័ររបស់និពន្ធនាយក " ក្នុងលក្ខណៈកាន់តែច្នៃប្រឌិតឡើង។

- ត្រូវចេះបង្កើត ឬគ្រប់គ្រងស្ថានការណ៍ដោយខ្លួនឯង! កុំរង់ចាំឱ្យប្រព័ន្ធផ្សព្វផ្សាយមករកអ្នក។ ត្រូវចេះផ្តួចផ្តើមគំនិតដោយខ្លួនឯង។ ប៉ុន្តែត្រូវឱ្យប្រាកដថាអ្នកមិនកំពុងខ្ជះខ្ជាយពេលវេលារបស់ពួកគេទេ។ ម្យ៉ាងវិញទៀត ត្រូវឱ្យប្រាកដថាអ្នកមានអ្វីដែលមានតម្លៃជាព័ត៌មានដើម្បីផ្តល់ឱ្យពួកគេ។

**ចូរចងចាំ :** ហ៊ីវ/អេដស៍ គឺជាបញ្ហាមួយដ៏ស្មុគស្មាញ។ ពាក្យពេចន៍របស់វាពិបាកយល់ ។មានអក្សរកាត់ជាច្រើន និងមានពាក្យពេទ្យដែលពិបាកយល់ជាច្រើន។

អ្នកកាសែតត្រូវធ្វើការក្រោមសំពាធជាច្រើន។ តាមធម្មតា ពួកគេគ្មានពេលវេលាដើម្បីធ្វើការស្រាវជ្រាវ ឬអានពីប្រវត្តិអ្វីទេ។ ព្រោះហេតុដូច្នេះហើយពួកគេតែងតែយល់ខុសពីហ៊ីវ/អេដស៍។ ជួនកាលអ្នកកាសែតក៏មានប្រើភាសាបំផ្លើសដែរនៅពេលដែលពួកគេសរសេរអំពីបញ្ហានេះពីព្រោះពួកគេគិតថាប្រការនេះនឹងធ្វើឱ្យវាកាន់តែធ្វើឱ្យចាប់អារម្មណ៍ឡើង។

ក្នុងនាមជាអ្នកធ្វើទំនាក់ទំនងផ្នែកហ៊ីវ/អេដស៍ យើងចាំបាច់ត្រូវតែស្វែងយល់ពីការលំបាកដែលអ្នកកាសែតត្រូវប្រឈមមុខដើម្បីឱ្យយើងអាចជួយពួកគេកាន់តែទទួលខុសត្រូវ និងមានវិជ្ជាជីវៈក្នុងអាជីពឡើង។

ហើយយើងត្រូវធ្វើជាគំរូល្អដោយខ្លួនឯង។ នេះមានន័យថានៅពេលដែលយើងនិយាយជាមួយប្រព័ន្ធផ្សព្វផ្សាយអំពីរឿងហ៊ីវ/អេដស៍ យើងត្រូវនិយាយឱ្យបានច្បាស់លាស់ ហើយសមញ្ញបំផុត។ យើងគួរតែដាក់ព័ត៌មានដែលស្មុគ្រស្មាញជាពិសេសនោះឱ្យទៅជាទម្រង់ជាលាយល័ក្ខអក្សរវិញ (ដូចជាចុល្លលិខិត ឬតារាងការពិត )ដើម្បីឱ្យអ្នកកាសែតអាចប្រើវាជាឯកសារយោងនៅពេលក្រោយដើម្បីឱ្យបានត្រឹមត្រូវ។

## យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយ ( Media Campaigns )

*មុនពេលដែលអ្នកអាចចាត់ចែងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយមួយដែលមានប្រសិទ្ធភាពបាន អ្នកចាំបាច់ត្រូវតែស្វែងយល់ពីប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុករបស់អ្នកសិន និងពីអ្វីដែលពួកគេគិតឃើញពីអ្នក ។ ចូរសាកល្បងចំណេះដឹងរបស់អ្នកដោយការឆ្លើយតបទៅនឹងសំនួរទាំងនេះ :*

១) តើអ្នកអាចបើកស្តាប់ស្ថានីយវិទ្យុណាខ្លះ? តើនរណាខ្លះស្តាប់ស្ថានីយទាំងនោះ?

២) តើនរណាជាមនុស្សដែលទាក់ទងនឹងវិទ្យុសំខាន់ជាងគេរបស់អ្នក?

៣) តើកម្មវិធីវិទ្យុអ្វីខ្លះដែលផ្តល់ឱកាសសំរាប់ការផ្សព្វផ្សាយ? តើមានកម្មវិធីវិទ្យុអ្វីខ្លះដែលអ្នកមិនទាន់សាកល្បង?

៤) ចុះចំណែកឯវិទ្យុសហគមន៍វិញ? តើមនុស្សទំនាក់ទំនងសំខាន់របស់អ្នកជានរណា?

៥) តើអ្នកអាច/បានប្រើកម្មវិធីទូរទស្សន៍អ្វីខ្លះ?

៦) កត់ត្រាឈ្មោះកាសែត និងទស្សនាវដ្ដីដែលអ្នកអាចរកទិញបាន ។ តើនរណាជាមនុស្សទំនាក់ទំនងរបស់អ្នកនៅក្នុងករណីនិមួយៗ?

៧) តើអ្នកមានស្គាល់មនុស្សដែលត្រូវទាក់ទងដើម្បីទាក់ទងជាមួយនៅទីភ្នាក់ងារសារព័ត៌មានជាតិរបស់អ្នកទេ?

៨) តើអ្នកគិតថាអ្វីទៅដែលជាមុខមាត់របស់អង្គការស្ថាប័នរបស់អ្នកនៅក្នុងប្រព័ន្ធផ្សព្វផ្សាយនោះ? ហេតុអ្វី? តើអ្នកចង់ផ្លាស់ប្តូរវាទេ?

*នៅពេលដែលអ្នកដឹងចម្លើយចំពោះសំនួរទាំងនេះហើយ អ្នកអាចចាប់ផ្តើមរៀបផែនការយុទ្ធនាការរបស់អ្នកហើយ ។*

១) កំណត់ទិសដៅរបស់អ្នក - តើអ្នកចង់ផ្សព្វផ្សាយព័ត៌មានអ្វី? តើអ្នកចង់ឱ្យទស្សនិកជនរបស់អ្នកធ្វើអ្វីខ្លះជាមួយនឹងព័ត៌មាននេះ? តើអ្នកចង់ឱ្យពួកគេផ្លាស់ប្តូរឥរិយាបទរបស់ពួកគេឬ? ឬក៏ធ្វើ

សកម្មភាពផ្សេងទៀត?

២) ត្រូវកំណត់ទស្សនិកជនដែលជាទីសដៅរបស់អ្នក ។ តើហេតុអ្វីបានជាពួកគេមិនបើកចំហរចំពោះសាររបស់អ្នក? តើអ្នកអាចបញ្ចុះបញ្ចូលពួកគេឱ្យស្តាប់តាមវិធីណា?

៣) កំនត់បញ្ហាគន្លិះរបស់អ្នក ហើយសំរេចរើសយកមុមព័តិមានដែលជា "ទំពក់" ទាក់ទាញការចាប់អារម្មណ៏របស់អ្នកកាសែត ។

៤) កំណត់ថាតើអ្នកចង់ដៅយកប្រព័ន្ធផ្សព្វផ្សាយណាមួយ និងតាមវិធីណា និងនៅពេលណា ។

៥) ស្វែងរកមុខមាត់មនុស្សរបស់សាច់រឿង - ដែលជាឧទាហរណ៏ពិតធ្វើឱ្យសាររបស់អ្នកមានជីវិត ។

៦) ត្រូវគិតពីការពិត និងភ័ស្តុតាងដើម្បីគាំទ្រសាររបស់អ្នក ។

៧) គិតពីឃ្លោងឃ្លា ឬពាក្យស្លោកគន្លិះដែលនឹងជួយធ្វើឱ្យគេចងចាំសាររបស់អ្នក ។

៨) ពិនិត្យមើលសេចក្តីរាយការណ៏ពីអតីតកាលរបស់ប្រព័ន្ធផ្សព្វផ្សាយ ។ តើអ្នកធ្លាប់ត្រូវគេបំផ្លើសសារទេកាលពីមុនមក? តើអ្នកចាំបាច់ត្រូវធ្វើការគ្រប់គ្រងការខូចខាតណាមួយទេ? តាមរបៀបណា? អ្វីខ្លះ?

៩) ត្រូវប្រុងប្រៀបខ្លួនឆ្លើយតបទៅនឹងទស្សនៈប្រឆាំងដោយអារម្មណ៏ស្ងប់ស្ងាត់ និងសមហេតុផល ។

១០) មុនពេលអ្នកធ្វើបទសម្ភាសន៏ណាមួយ ត្រូវហ្វឹកហាត់អ្វីដែលអ្នកត្រូវនិយាយជាមួយសហការី ។ អ្នកអាចថែមទាំងសមល្ខោនសំរាប់កិច្ចការនេះដោយឱ្យសហការីរបស់អ្នកដើរតួធ្វើជាអ្នកកាសែត ។



## ការសរសេរសេចក្តីប្រកាសព័ត៌មាន ( Writing Press Releases )

នេះគឺជារឿងមួយដែលអ្នកប្រហែលជាមិនចង់ស្តាប់ទេ។ មានសេចក្តីប្រកាសព័ត៌មានចំនួន ៩០% នៅទីបំផុតបានបញ្ចប់នៅក្នុងធុងសម្រាម! តើព្រោះហេតុអ្វីទៅ? ពីព្រោះអង្គការស្ថាប័នទាំងឡាយតែងតែភ័ន្តច្រឡំសាច់រឿងដែលមានតម្លៃជាមួយនឹងសាច់រឿងដែលមានតម្លៃត្រឹមតែធ្វើជាព័ត៌មាន ។ ពួកគេភ្លេចគិតពីអ្វីដែលអ្នកកាសែតត្រូវការ។ នេះគឺជារឿងមួយគួរឱ្យអាណិតណាស់ពីព្រោះប្រសិនបើអ្នកសរសេរសេចក្តីប្រកាសព័ត៌មានដ៏ល្អពិតប្រាកដមួយនោះ អ្នកប្រហែលជានឹងប្រទះឃើញថាវាត្រូវគេយកទៅប្រើប្រាស់ជាសាច់រឿងមួយដោយគ្មានការផ្លាស់ប្តូរច្រើនទេ។

ហេតុនេះ នេះគឺជាគំនិតខ្លះៗដែលបានមកពីអ្នកកាសែតអំពីអ្វីដែលពួកគេចូលចិត្ត និងអ្វីដែលពួកគេមិនចូលចិត្តស្តីពីសេចក្តីប្រកាសព័ត៌មានដែលពួកគេបានទទួល។

ក-**<u>អ្វីដែលអ្នកកាសែតមិនចូលចិត្ត :</u>**

- សេចក្តីប្រកាសព័ត៌មានតែងតែវែងពេក-តែមួយទំព័រល្មមហើយ។
- សេចក្តីប្រកាសព័ត៌មានមិនមកដល់ទាន់ពេលវេលាដើម្បីឱ្យអ្នកកាសែតធ្វើសេចក្តីរាយការណ៍ពីសាច់រឿង។
- មានការប្រើភាសារញ៉េរញ៉ៃច្រើនពេក។
- សេចក្តីប្រកាសព័ត៌មានមិននិយាយចូលចំណុចភ្លាមៗទេ។
- គេភ្លេចសរសេរចំណុចលំអិតសំខាន់ៗ ( ដូចជាពេលវេលា កាលបរិច្ឆេទ ទីកន្លែង ។ល។)
- ជួនកាលគេភ្លេចផ្តល់លេខទាក់ទងច្រើនជាងមួយ : វាតែងតែពិបាកក្នុងការទាក់ទងទៅលេខឯទៀតក្នុងការិយាល័យ។

- គេតែងតែច្រឡំសាច់រឿងដែលមានតម្លៃជាមួយសាច់រឿងដែលមានតម្លៃត្រឹមតែជាព័ត៌មាន! បន្ទាប់មកពួកគេព្យាយាមធ្វើឱ្យអ្នកកាសែតមានអារម្មណ៍ដែលមានកំហុសប្រសិនបើអ្នកកាសែតនោះមិនបានរាយការណ៍ពីសាច់រឿងនោះទេ។
- សេចក្តីប្រកាសព័ត៌មានភាគច្រើនមិនឆ្លុះបញ្ចាំងពីមុមព័ត៌មានទេ។
- គេមិនបានគិតពីតម្រូវការខុសប្លែកគ្នារបស់កាសែតប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ទេ ឬពីតម្រូវការជាក់លាក់របស់កាសែតជាតិឡើយ។

ខ-<u>អ្វីដែលអ្នកកាសែតចូលចិត្ត</u>

- អ្នកកាសែតចូលចិត្តការដកស្រង់ពាក្យនៅក្នុងសេចក្តីប្រកាសព័ត៌មាន-ពួកគេប្រហែលជាមិនប្រើប្រាស់វាទេ ប៉ុន្តែយ៉ាងហោចណាស់ក៏ពួកគេមានការជ្រើសរើសដែរ។
- វាជាការល្អប្រសើរដើម្បីផ្តល់ចំណុចលំអិត នៃឱកាសថតរូប-ឬក៏រូបថតអ្វីខ្លះដែលអាចរកបាន។
- ប្រសិនបើសមស្របគួរស្នើឡើងពីមនុស្សដែលអាចផ្តល់កិច្ចសម្ភាសន៍ (អ្នកកាសែតប្រហែលជាអាចចង់សរសេរសាច់រឿង)។
- ត្រូវទូរស័ព្ទបញ្ជាក់ឱ្យបានញឹកញាប់! ប៉ុន្តែកុំពន្យាពេលប្រសិនបើអ្នកកាសែតនោះគ្មានពេលដើម្បីនិយាយនៅពេលដែលអ្នកទូរស័ព្ទហៅ។ ជានិច្ចកាលអ្នកកាសែតតែងតែព្យាយាមតាមឱ្យទាន់ពេលវេលា។ ចូរពិនិត្យមើលថាតើពួកគេអាចនិយាយជាមួយអ្នកនៅពេលណា។
- ពិចារណាពីការបញ្ចូលតារាងការពិតជាមួយនឹងសេចក្តីប្រកាសព័ត៌មានរបស់អ្នកនៅកន្លែងណាដែលសមស្រប។
- ត្រូវធ្វើឱ្យថ្មីរហូតនូវបញ្ជីទាក់ទងប្រព័ន្ធផ្សព្វផ្សាយរបស់អ្នក...វាហាក់ដូចជាអ្នកគ្មានវិជ្ជាជីវៈអីចឹងប្រសិនបើអ្នកចេះតែបញ្ជូនសេចក្តីប្រកាសព័ត៌មានទៅឱ្យនរណាម្នាក់ដែលលែងធ្វើការហើយនោះ!

## ការគ្រប់គ្រងការសម្ភាសន៍តាមវិទ្យុ ( Handling Radio Interview )

ក-<u>សុន្ទរកថាខ្លីៗ</u> ( Soundbites )

*ជាញឹកញាប់អ្នកកាសែតវិទ្យុ នឹងទូរស័ព្ទមកសុំឱ្យអ្នកមានយោបល់មួយដ៏ឆាប់រហ័ស (ដែលពួកគេថតចម្លង )ស្តីពីបញ្ហានៅពេលបច្ចុប្បន្ន។ តាមធម្មតា ពួកគេត្រូវការយោបល់របស់អ្នកនៅពេលឥឡូវនេះហេតុនេះអ្នកគ្មានពេលច្រើនដើម្បីត្រៀមខ្លួនទេ។ តើអ្នកគួរចងចាំអ្វីខ្លះ?*

- កុំខ្វះខ្វាយពាក្យ-ត្រូវនិយាយឱ្យខ្លី ហើយសមញ្ញបំផុត។
- និយាយជាប្រយោគច្បាស់លាស់ មានលក្ខណៈវិជ្ជមាន។ ព្យាយាមកុំនិយាយអវិជ្ជមាន។
- ត្រូវស្រមៃថាអ្នកកំពុងនិយាយជាមួយអ្នកស្តាប់តែម្នាក់គត់ និងធ្វើឱ្យបញ្ហានោះក្លាយជាការពិតសំរាប់គាត់។
- ជៀសវាងកុំប្រើស្ថិតិដែលគ្មានន័យ។ ជំនួសពីនោះ ត្រូវរកឱ្យចំចំណុច។
- កុំព្យាយាមធ្វើដូចជាអ្នកជំនាញការ ឬជាមន្ត្រីម្នាក់។ ត្រូវរក្សាសម្លេងស្និទ្ធស្នាលបែបវិជ្ជាជីវៈ។ ជានិច្ចកាល អ្នកគួរតែឆ្លុះបញ្ចាំងរូបភាពរបស់អង្គការស្ថាប័នរបស់អ្នកនៅគ្រប់ចំណុចដែលអ្នកនិយាយជូសមុខឱ្យវា។
- ប្រសិនបើអ្នកមានអារម្មណ៍ច្រាសច្រាល ត្រូវដកដង្ហើមឱ្យវែង ហើយសម្រួលបំពង់ក និងស្មារបស់អ្នក។
- នៅពេលអ្នកបញ្ចប់ហើយ ត្រូវឈប់! អ្នកកាសែត នឹងសួរអ្នកនូវសំនួរផ្សេងទៀតប្រសិនបើចាំបាច់។

ខ-<u>បទសម្ភាសន៍វែង :</u>

- មុនពេលដែលអ្នកចាប់ផ្តើម ត្រូវសុំឱ្យអ្នកកាសែតសង្ខេបជូនអ្នកពីអ្វីដែលគេចង់បានពីអ្នក (តើអ្នកចង់តបទសម្ភាសន៍នោះមានរយៈពេលត្រឹមណា? តើអ្នកចង់ធ្វើសេចក្តីរាយការណ៍ពីវិស័យ

ជារូមអ្វីខ្លះ?) តែកុំសង្ឃឹមថាអ្នកកាសែតនឹងផ្តល់បញ្ជីសំនួរដល់អ្នកនោះ-វាមិនមែនជាការងារគេទេ!

- មុនពេលដែលអ្នកចាប់ផ្តើម ចូរគិតពីសារសំខាន់ដែលអ្នកចង់ផ្សព្វផ្សាយទោះបីជាគេមិនសួរអ្នកពីសំនួរពិតប្រាកដដែលអ្នកចង់ក៏ដោយ ។ កុំព្យាយាមញាត់បញ្ចូលសារសំខាន់ៗឱ្យលើសពីបីព្រោះទស្សនិកជនរបស់អ្នកមិនអាចចាំវាទាំងអស់បានទេ ។
- ប្រសិនបើអ្នកកាសែតមិនសួរអ្នកពីសំនួរដែលអ្នកចង់បាននោះ ត្រូវកាច់បង្វែរការសន្ទនានោះដោយសុភាពដើម្បីឱ្យខ្លួនអ្នកអាចបញ្ចេញចំណុចគន្លឹះៗបាន ។
- កុំមួម៉ៅប្រសិនបើអ្នកកាសែតសួរសំនួរពិបាកៗ ។ ព្រោះពួកគេមានបំនងធ្វើដូច្នោះហើយ ហើយវាមិនមានន័យថាអ្នកនៅជ្រុងម្ខាងទៀតដែរ ។
- ត្រូវចងចាំពីអ្នកស្តាប់ពិសេសតែម្នាក់គត់របស់អ្នក ហើយនិយាយទៅរកគាត់ទោះបីជាអ្នកកំពុងឆ្លើយតបសំនួរជាច្រើនពីអ្នកកាសែត ។
- បន្ទូរអារម្មណ៍ - អ្នកនៅទីនោះដើម្បីធ្វើទំនាក់ទំនង!

<u>ចងចាំថា :</u> ប្រសិនបើអ្នកត្រៀមខ្លួនដើម្បីធ្វើបទសម្ភាសន៍មួយនោះ ចូរគិតពីសំនួរទាំងឡាយដែលអ្នកមិនចង់ឱ្យអ្នកកាសែតសួរអ្នក! មុនពេលធ្វើសម្ភាសន៍ ត្រូវហ្វឹកហាត់ពីរបៀបឆ្លើយតបទៅនឹងសំនួរទាំងនេះដើម្បីឱ្យអ្នកនិយាយទៅក្នុងអារម្មណ៍ស្ងប់ស្ងាត់ និងបែបវិជ្ជាជីវៈ ។



## គ. ការជជែកកំសាន្តតាមវិទ្យុ ( Radio Talk Shows )

កម្មវិធីជជែកកំសាន្តអាចជាឱកាសមួយដ៏អស្ចារ្យដើម្បីរកឱ្យឃើញថាតើប្រជាជនកំពុងគិតអ្វីពីអង្គការស្តាប័នរបស់អ្នក និងដើម្បីសហការជាមួយពួកគេនៅក្នុងលក្ខណៈបែបវិជ្ជាជីវៈ និងស្និទ្ធស្នាល ។

ប៉ុន្តែ កម្មវិធីជជែកកំសាន្តក៏អាចធ្វើឱ្យមានការភិតភ័យដែរ ។ តើហេតុអ្វីទៅ? ពីព្រោះអ្នកមិនអាចមើលឃើញមនុស្សដែលកំពុងទូរស័ព្ទចូលមក! ចំណុចនេះហើយដែលធ្វើឱ្យអ្នកមានអារម្មណ៏ច្រាសច្រាលជាងធម្មតា និងមានលក្ខណៈការពារខ្លួនកាន់តែច្រើន ។

នៅពេលដែលចាត់ចែងកម្មវិធីជជែកកំសាន្ត ប្រការដែលរឹតតែសំខាន់ទៀតនោះ គឺត្រូវសំរួលអារម្មណ៏ ញញឹម និងត្រូវសម្តែងសមានចិត្តជាមួយអ្នកទូរស័ព្ទមក ។ ប្រសិនបើអ្នកទូរស័ព្ទចូលមកខឹង ឬមានមនោសញ្ចេតនានោះ ត្រូវព្យាយាមស្វែងយល់ថាហេតុអ្វីបានជាពួកគេមានអារម្មណ៏បែបនេះ ។ កុំនិយាយទៅរកគេដូចជាសត្រូវពីពេលណាមកនោះ ។

ព្យាយាមនិយាយពាក្យសម្តីខ្លះដូចនេះ :

*" ខ្ញុំអាចស្តាប់ឮថាអ្នកមានអារម្មណ៏ខ្លាំងណាស់អំពីបញ្ហានេះ ។ តើអ្នកអាចជួយខ្ញុំឱ្យយល់បានទេថាហេតុអ្វីបានជាអ្នកមានអារម្មណ៏បែបនេះ? "*



## **ចំណុចដែលមានប្រយោជន៍សំរាប់ទូរទស្សន៍** ( Tips for TV )

ចំណុចមានប្រយោជន៍ជាច្រើនដែលត្រូវផ្ដល់ជូនសំរាប់វិទ្យុក៏ពាក់ព័ន្ធនឹងទូរទស្សន៍ស្មើគ្នាដែរ ។ ប៉ុន្តែទូរទស្សន៍មានឧបសគ្គពិសេសមួយ ។ ទាំងអស់គឺនិយាយពីរូបភាព ។

ចូរចាំថា : ជួនកាលកាមេរាចិត្តអាក្រក់ណាស់ ។ ហេតុនេះ ប្រសិនបើអ្នកមានទឹកមុខមិនស្រួលទេ អ្នកមើល នឹងមិនអាចផ្ដោតទៅលើសាររបស់អ្នកឡើយ ។ រូបរាងរបស់អ្នកអាចជាគន្លិះឆ្ពោះទៅរកជ័យជំនះ ឬបរាជ័យ ។

ហេតុនេះ នេះគឺជាចំណុចមានប្រយោជន៍ខ្លះៗជួយធ្វើឱ្យអ្នកមានទឹកមុខស្រួល និងជាអ្នកមានវិជ្ជាជីវៈនៅលើកញ្ចក់ទូរទស្សន៍ :

- **កុំស្លៀកពាក់ឆើតពេក**-ជៀសវាងពណ៌ឆើតពេក រូបធំៗ ឆ្នូតៗ និងគ្រឿងអលង្ការដែលធ្វើឱ្យទាក់ទាញ ( ដែលអាចឆ្លុអនឹងពន្លឺ ) ។
- សំលៀកបំពាក់ពណ៌សអាចបង្កឱ្យមានបញ្ហា ។
- **កុំពាក់វ៉ែនតាខ្មៅ**- វាធ្វើឱ្យអ្នកមើលទៅគួរឱ្យខ្លាច ។
- ប្រសិនបើអ្នកកំពុងត្រូវគេសម្ភាសន៍នៅក្នុងស្ទូឌីយោ ចូរចាំថាពន្លឺភ្លើងក្ដៅខ្លាំងណាស់ ។ ត្រូវស្លៀកសំលៀកបំពាក់ណាដែលមិនធ្វើឱ្យអ្នកបែកញើស ។
- ចាំថា : " **ខ្នងរបស់ខ្ញុំវែង ហើយធំ** " *( ដំបូន្មាននេះត្រូវបានផ្ដល់ឱ្យនៅកន្លែងណាមួយក្នុងកំណត់ចំណាំទាំងនេះ ) ។*
- **មិនត្រូវធ្វើមុខធុញ** -សូម្បីតែអ្នកធុញក៏ដោយ!
- ត្រូវសម្លឹងចំមុខអ្នកធ្វើសម្ភាសន៍ និងកុំខ្លាចនឹងញញឹម ឬធ្វើកាយវិការនៅពេលណាក៏ដោយដែលអ្នកត្រូវធ្វើដូច្នោះទៅតាមលក្ខណៈធម្មជាតិ ។ ប៉ុន្តែ ត្រូវជៀសវាងកាយវិការណាបែបព្រៃដែលអាចធ្វើឱ្យអ្នកមើលទៅមិនថ្លៃថ្នូរ ។

- ដូចជាមួយវិទ្យុដែរ ត្រូវស្រមៃថាអ្នកកំពុងនិយាយទៅកាន់មនុស្សតែម្នាក់ គឺជាមនុស្សម្នាក់ដែលចាប់អារម្មណ៍នូវអ្វីដែលអ្នកកំពុងនិយាយ ។
- ក៏ដូចជាមួយវិទ្យុដែរ ត្រូវឱ្យពិត កក់ក្តៅ និងមានមនុស្សធម៌ ។ កុំព្យាយាមធ្វើឱ្យគេចាប់អារម្មណ៍ ត្រូវផ្តោតលើការបង្ហាញខ្លួនឯងឱ្យបានសមញ្ញតាមដែលអាចធ្វើទៅបាន ។

**សូមឱ្យមានសំណាងល្អ!**

